ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សូមគោរពជូន
# លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
# និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

**តាមរយៈ:** លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ:** របាយការណ៍សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍ (MGI) និងការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។

ថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ៨ និង៣០ នាទីព្រឹក នៅសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ មានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍ (MGI) និងការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមសម្របសម្រួលដោយអង្គការ IOM ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

## I.សមាសភាពចូលរួម

១.លោកស្រី **គ្រីស្ទីន ផាភូ** តំណាងបេសកកម្មអង្គការ IOM
និងជាតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា
២.លោកជំទាវ **តាន់ ខ្វចឆេង** រដ្ឋលេខាធិការក្រសួងសុខាភិបាល
៣.ឯកឧត្តម **ហ៊ឹ ខុឡូរី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
៤.ឯកឧត្តម **ប៉ូច ប៊ុណ្ណាក់** រដ្ឋលេខាធិការក្រសួងផែនការ
៥.លោកជំទាវ **កែវ ចរិយា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៦.លោកជំទាវ **ឡុង សុផល្លី** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី
៧.ឯកឧត្តម **សុន ពិសិដ្ឋ** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
៨.លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណា សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ
៩.ឯកឧត្តម នាយឧត្តមសេនីយ៍ **ឃុន សំបូរ** អគ្គនាយករង អគ្គនាយកដ្ឋានអន្តោប្រវេសន៍
១០.លោកជំទាវ ឧត្តមសេនីយ៍ឯក **លឹម រស្មី** អគ្គនាយករង អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
១១.ឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉ែម ច័ន្ទណារ៉ូ** អគ្គលេខាធិការរង គ.ជ.ប.ជ
១២.លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ
១៣.លោកឧត្តមសេនីយ៍ទោ **រស់ សុខធឿន** ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនទឹក
14. លោកឧ.ស. ស៊ិន [illegible]

១៤.តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
១៥.តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា
១៦.តំណាងទីចាត់ការការងារព្រំដែន នៃអគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ
១៧.តំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ
១៨.មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

សរុបចំនួន ៤១ រូប ស្រីចំនួន ១១ រូប ។

## II.គោលបំណង នៃអគ្គសិក្ខាសាលា

- គាំទ្រដល់គោលនយោបាយទេសន្តរប្រវេសន៍របស់ប្រទេសនីមួយៗ ដើម្បីឲ្យមានការគ្រប់គ្រងល្អ តាមរយៈការជួយវាយតម្លៃលើភាពគ្រប់ជ្រុងជ្រោយ នៃរចនាសម្ព័ន្ធអភិបាលកិច្ចទេសន្តរប្រវាសន៍ និងកំណត់អាទិភាពនានា ។
- MGI អាចត្រូវបានប្រើសម្រាប់ជំរុញឲ្យមានការពិភាក្សា លើរចនាសម្ព័ន្ធគោលនយោបាយទេសន្តរប្រវេសន៍របស់ប្រទេសនីមួយៗ នៅក្នុងរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ហើយវាអាចជាជំនួយក្នុងការវាយតម្លៃ ថាតើរចនាសម្ព័ន្ធដែលមានស្រាប់ជាច្រើនឆ្នាំមកនេះ អាចជួយស្រាយបញ្ហាប្រឈម និងឱកាសនានានៅក្នុងស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ននេះដែរឬទេ ។

## III.ប្រសាសន៍ស្វាគមន៍

**លោកស្រី គ្រីស្ទីន ផាកូ** តំណាងបេសកកម្មអង្គការ IOM និងជាតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា បានថ្លែងអំណរគុណចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំតំណាងក្រសួង ស្ថាប័នទាំងអស់ក្នុងការអញ្ជើញមកចូលរួមក្នុងសិក្ខាសាលានាពេលនេះ។ លោកស្រី **គ្រីស្ទីន ផាកូ** បានលើកឡើងអំពីចំណុចសំខាន់ៗ នៃ MGI ដែលយើងនឹងធ្វើការងារជាមួយគ្នារួមមាន៖

- ធ្វើការវាយតម្លៃបឋម នៃវឌ្ឍនភាពទាំងមូលដែលបានធ្វើការអនុវត្ត ការបង្រួមជាសកលសម្រាប់ចំណាកស្រុក (GCM) ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។
- បង្ហាញពីបញ្ហាប្រឈមទូទៅ ឱកាស ភាពចន្លោះប្រហោង និងបញ្ហាដែលកំពុងលេចឡើង និងពិភាក្សាអំពីអាទិភាព និងរំលេចធនធានដែលត្រូវការទៅក្នុងការអនុវត្ត GCM ។
- ផ្តល់នូវវេទិការួមមួយសម្រាប់អន្តរកម្មរវាងអ្នកពាក់ព័ន្ធទាំងអស់ និងផ្លាស់ប្តូរមេរៀន បទពិសោធន៍ដែលមាន និងការអនុវត្តល្អរវាងពួកគេ និងអ្នកពាក់ព័ន្ធ និងតំបន់ផ្សេងទៀត ។
- ពិភាក្សាលើវិស័យសក្តានុពលក្នុងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ស្តីពីការធ្វើចំណាកស្រុកអន្តរជាតិស្របតាមចក្ខុវិស័យ និងគោលការណ៍ណែនាំរបស់ GCM ។
- ជួយសម្រួលដល់ការបង្កើតនូវរបកគំហើញ និងអនុសាសន៍សំខាន់ៗ ដើម្បីជូនដំណឹងដល់វេទិកាពិនិត្យការធ្វើចំណាកស្រុកអន្តរជាតិ (IMRF) ឆ្នាំ២០២២ ។ កិច្ចប្រជុំនេះ អនុម័តនូវវិធីសាស្ត្ររួមបញ្ចូលគ្រប់ទាំងរដ្ឋាភិបាល និងសង្គមទាំងមូល ហើយនឹងពិនិត្យឡើងវិញនូវគ្រប់ទិដ្ឋភាពទាំងអស់ នៃ GCM យោងតាមចក្ខុវិស័យ និងគោលការណ៍ណែនាំអន្តរក្រសួង ។
- ផ្តល់ព័ត៌មានសម្រាប់ការត្រួតពិនិត្យ លើតំបន់អាស៊ីប៉ាស៊ីហ្វិក នៃការអនុវត្តការបង្រួបបង្រួមជាសកលសម្រាប់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលនឹងត្រូវបានរៀបចំរួមគ្នាដោយគ

ណៈកម្មការសេដ្ឋកិច្ច និងសង្គម សម្រាប់អាស៊ីប៉ាស៊ីហ្វិក (ESCAP) និងបណ្ដាញអង្គការសហប្រជាជាតិប្រចាំតំបន់ ស្ដីពីការធ្វើចំណាកស្រុកសម្រាប់អាស៊ី និងអាស៊ីប៉ាស៊ីហ្វិក នៅឯមជ្ឈមណ្ឌលសន្និសិទអង្គការសហប្រជាជាតិនៅទីក្រុងបាងកក និងការថតសម្លេងជាវីដេអូ នាថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ ២០២១ ។

លោកស្រី **ត្រីស្ទីន ផារ៉ូ** បានបន្ថែមថា តាមរយៈចំណុចសំខាន់ៗខាងលើនេះ គឺជាជំហានដែលបោះទៅមុខមួយសម្រាប់យើងទាំងអស់គ្នា ដើម្បីអាចមានជាផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការអនុវត្តគោលដៅដែលបានជ្រើសរើសរបស់ (GCM) ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ថា ជាបឋម ក្នុងនាម **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្នុងនាមខ្លួនខ្ញុំផ្ទាល់មានសេចក្ដីសោមនស្សរីករាយ ដោយបានរួមសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) រៀបចំសិក្ខាសាលាថ្នាក់ជាតិនេះឡើងដើម្បីពិនិត្យ ពិភាក្សាលើរបាយការណ៍សូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍ និងការរៀបចំផែនការសកម្មភាពអនុវត្តកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់ចំពោះបញ្ហាទេសន្តរប្រវេសន៍ ដែលក្នុងនោះ មានប្រជាជនកម្ពុជាពេញវ័យ បានចេញទៅស្វែងរកការងារនៅក្រៅប្រទេស រហូតដល់ជាងមួយលាននាក់ ដែលជាតួលេខដ៏ខ្ពស់មួយ បើប្រៀបធៀបទៅនឹងចំនួនប្រជាជនដែលជាកម្លាំងពលកម្មសម្រាប់ឆ្លើយតបទៅនឹងសេចក្ដីត្រូវការក្នុងការអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គមជាតិ ។ ក្នុងរយៈពេលប្រមាណ២ទសវត្សរ៍កន្លងមកនេះកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ជាមួយបណ្ដាប្រទេស ដែលមានពលករទេសន្តរប្រវេសន៍កម្ពុជា ត្រូវបានធ្វើឡើងតាមអនុស្សរណៈ និងកិច្ចព្រមព្រៀងនានា តែនៅមិនទាន់គ្រប់គ្រាន់ក្នុងការធ្វើឲ្យជនទេសន្តរប្រវេសន៍មានភាពកក់ក្ដៅ និងបញ្ចៀសបានពីភាពរងគ្រោះ និងការកេងប្រវ័ញ្ចនៅឡើយ ដែលទាមទារឲ្យមានការតាមដាន ត្រួតពិនិត្យ និងមានវិធានការ កាន់តែជាក់លាក់ និងហ្មត់ចត់បន្ថែមទៀត ក្នុងកិច្ចសហប្រតិបត្តិការ ។

**លោកជំទាវ** មានប្រសាសន៍លើកឡើងថា ចាប់តាំងពីកតិកាសញ្ញាពិភពលោក ស្ដីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ ត្រូវបានអនុម័ត នាខែធ្នូ ឆ្នាំ២០១៨ មក ព្រះរាជាណាចក្រកម្ពុជា ដែលជារដ្ឋសមាជិកនៃកតិកាសញ្ញា និងបានចូលរួមពេញទំហឹង ក្នុងដំណើរការរៀបចំ ពិគ្រោះយោបល់រហូតដល់ចូលរួមអនុម័តកតិកាសញ្ញាពិភពលោកនេះ នៅតែបន្តប្ដេជ្ញាចិត្តជំរុញការអនុវត្តឲ្យបានទទួលលទ្ធផលល្អប្រសើរ ដើម្បីការពារសិទ្ធិ ផលប្រយោជន៍ និងសេចក្ដីថ្លៃថ្នូរ របស់ពលករដែលជាពលរដ្ឋកម្ពុជា រួមទាំងពលករដែលចូលមកធ្វើការនៅកម្ពុជា ក៏ដូចជាដើម្បីផលប្រយោជន៍ជាតិ ដែលបានមកពីការងារនៅក្រៅប្រទេសរបស់ពលករ និងដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយ ដែលពលករប្រឈមក្នុងអំឡុងពេលធ្វើទេសន្តរប្រវេសន៍ការងារ និងផលប៉ះពាល់ ព្រមទាំងដើម្បីលើកកម្ពស់គុណតម្លៃនៃទេសន្តរប្រវេសន៍ការងារ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសបញ្ជូន និងប្រទេសទទួលក្នុងការគ្រប់គ្រង និងគាំពារពលករទេសន្តរប្រវេសន៍ ។ ព្រះរាជាណាចក្រកម្ពុជា បានសម្រេចជ្រើសរើសយកគោលបំណងពីរ ក្នុងចំណោមគោលបំណងទាំង២៣ ដែលត្រូវបានកំណត់ក្នុងកតិកាសញ្ញា ដើម្បីធ្វើជាមូលដ្ឋានបង្អែកក្នុងការរៀបចំសកម្មភាពសម្រាប់អនុវត្តឲ្យបានជាក់លាក់ និងទទួលបានលទ្ធផលតាមការរំពឹងទុក ។

លោកជំទាវ មានប្រសាសន៍បញ្ជាក់បន្ថែមថា សិក្ខាសាលានាថ្ងៃនេះ ពិតជាមានសារសំខាន់ ក្នុងការពិនិត្យពិភាក្សាលើរបាយការណ៍សូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍របស់ព្រះរាជាណាចក្រកម្ពុជា ដែលអង្គការ IOM ក្នុងតួនាទីជាទីប្រឹក្សា និងជំនួយការប្រតិបត្តិតាមបណ្តាប្រទេសសមាជិកក្នុងពិភពលោក ជាពិសេស ប្រចាំនៅកម្ពុជា បានខិតខំស្រាវជ្រាវ និងចងក្រងសម្រាប់ជារបាយការណ៍បឋមដើម្បីធ្វើជាឧបករណ៍វាស់ស្ទង់នូវបម្រែបម្រួលប្រសើរឡើងនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ និងដើម្បីប្រើប្រាស់ជាខ្នាតវាស់នៃអភិបាលកិច្ចទេសន្តរប្រវេសន៍ ចំណុចខ្វះខាតដែលត្រូវកែលម្អ និងបំពេញបន្ថែមឲ្យរឹតតែប្រសើរឡើង ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពសេដ្ឋកិច្ចរបស់ជនទេសន្តរប្រវេសន៍ គ្រួសារ សហគមន៍ សង្គម និងប្រទេសជាតិ ។ យើងនឹងពិនិត្យលើកម្រងសំណួររបស់អង្គការ UNESCAP ដើម្បីបកស្រាយពន្យល់ និងផ្តល់ទិន្នន័យ អំពីកិច្ចខិតខំប្រឹងប្រែង និងចំណុចខ្វះខាតដែលត្រូវបំពេញបន្ថែម សម្រាប់ការអនុវត្តបន្តទៀតផងដែរ ។ យើងនឹងពិភាក្សារកធាតុចូលសម្រាប់ការរៀបចំផែនការសកម្មភាព ដើម្បីអនុវត្តកតិកាសញ្ញាពិភពលោក ដែលឆ្លើយតបទៅនឹងគោលបំណងពីរ ដែលក្រសួងស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាលបានជ្រើសរើសរួមគ្នា កាលពីខែកុម្ភៈ ឆ្នាំ២០២០កន្លងទៅនេះ និងបានទទួលការឯកភាពពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាល ផងដែរ ។ **លោកជំទាវ** បានរំលឹកផងដែរថា នៅឆ្នាំ២០២២ រដ្ឋសមាជិកនៃកតិកាសញ្ញា នឹងត្រូវធ្វើរបាយការណ៍ស្តីពីភាពជឿនលឿនក្នុងការអនុវត្តកតិកាសញ្ញា ដែលប្រទេសនីមួយៗ បានសម្រេចជ្រើសរើសគោលបំណងដែលឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃប្រទេសរៀងៗខ្លួន ។ ចំពោះការប្រមូលទិន្នន័យទាំងអស់ពាក់ព័ន្ធនឹង MGI ខាងក្រុមការងារអង្គការ IOM មិនទាន់បានប្រមូលផ្តុំគ្រប់ជ្រុងជ្រោយនៅឡើយ ហើយក៏មានទិន្នន័យ ឬរបាយការណ៍មួយចំនួនក៏មានការប្រែប្រួល ។ **លោកជំទាវ** បានស្នើដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកាទាំងអស់ នៃអង្គសិក្ខាសាលា ជួយផ្តល់ជាមតិយោបល់ លើកពីបទពិសោធន៍ ក្នុងការកែសម្រួលរបាយការណ៍សូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍ និងការអនុវត្តកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។

## IV.ការធ្វើបទបង្ហាញ

លោកស្រី MARTA WALKOWIAK មន្ត្រីអភិវឌ្ឍកម្មវិធី និងទំនាក់ទំនង នៃអង្គការ IOM បានធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលានេះ ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍ (MGI) ក្នុងនោះ លោកស្រីបានលើកអំពី ១.ខ្លឹមសារ និងគោលបំណងរបស់ MGI ២.ដំណើរការ MGI ៣.សារប្រយោជន៍ MGI ។ លោកស្រីក៏បានបន្ថែមថា ក្រុមការងាររបស់អង្គការ IOM បានធ្វើការពិភាក្សាអំពីសូចនាករ និងបានជ្រើសរើសសូចនាករសរុបជាង ៩០ ទាក់ទងការអនុវត្តកតិកាសញ្ញាពិភពលោក ហើយត្រូវបានបញ្ចូលត្រឹម ៦ ចំណុចធំៗ នៃអភិបាលកិច្ចទេសន្តរប្រវេសន៍ល្អ ។

**លោក ភាវ ខៃ** អ្នកសម្របសម្រួល នៃអង្គការ IOM បានឡើងធ្វើបទបង្ហាញអំពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍ (GMI) ជាមួយគ្នានេះដែរ លោក ភាវ ខៃ បានលើកឡើងអំពីគោលបំណងរបស់ MGI ធំៗចំនួន ២ ដែលមានខ្លឹមសារនៅក្នុង ចំណុច (II) ខាងលើ និងរបកគំហើញចំនួន ៦ រួមមាន៖ ១.សិទ្ធិរបស់ជនទេសន្តរប្រវេសន៍ ២.យុទ្ធសាស្ត្រផ្តោតលើរដ្ឋាភិបាលទាំងមូល ៣.ភាពជាដៃគូ ៤.សុខុមាលភាពរបស់ជនទេសន្តរប្រវេសន៍ ៥.អន្តរាគមន៍សម្រាប់ជនទេសន្តរប្រវេសន៍ក្នុងអំឡុងពេលមានវិបត្តិ ៦.ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ។ លោក ភាវ ខៃ ក៏បានធ្វើការពន្យល់បង្ហាញដោយសង្ខេបលើប្រធានបទ តាមចំណុចនីមួយៗជូន លោកជំទាវប្រធានអង្គ

សិក្ខាសាលា ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាគណៈធិបតី និងសមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងមូលផងដែរ ដើម្បីជាគន្លឹះក្នុងការពិភាក្សា ផ្តល់មតិយោបល់ បំពេញបន្ថែមនូវចំណុចខ្វះចន្លោះ ឬកែសម្រួលនូវខ្លឹមសារត្រង់ណាមួយពាក់ព័ន្ធនឹងរបាយការណ៍ សូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍នេះ ។ លោក ភារ៉ា ខៃ ក៏បានលើកឡើងអំពីចំណុចល្អ និងខ្វះខាត បញ្ហាប្រឈមមួយចំនួនដែលបានអនុវត្តកន្លងមក ។

**V.មតិចូលរួម**

១.**លោកជំទាវ រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ មានមតិចូលរួមពាក់ព័ន្ធនឹងទំព័រទី០៧ ដែលលើកឡើងអំពីច្បាប់ស្តីសញ្ជាតិ ឆ្នាំ១៩៩៦ តែច្បាប់នេះត្រូវបានសភាបានអនុម័តថ្មីរួចហើយនាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ក្នុងនោះដែរនៅក្នុងមាត្រា៣៧ បានបញ្ជាក់ច្បាស់ថាច្បាប់ចាស់ ឆ្នាំ១៩៩៦ ត្រូវបាននិរាករណ៍ ហើយសូមពិនិត្យលើច្បាប់ថ្មីថាគួរដាក់បញ្ចូលត្រង់ចំណុចណា។ ចំណុចមួយទៀត(ទំព័រ១៤) គឺបញ្ហា អនុស្សរណៈ (MOU) ថ្មីៗនេះយើងបានកែប្រែខ្លឹមសារជាមួយប្រទេសថៃ និងប្រទេសវៀតណាម ហើយក៏បានចុះកិច្ចព្រមព្រៀងរួចហើយដែរ លើកលែងតែជាមួយម៉ាឡេស៊ីទេ ដែលមិនមានការប្រែប្រួលគឺចុះអនុស្សរណៈស្តីពីការជ្រើសរើសពលករ មិនមែនពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនោះទេ ។

២.**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ចូលរួមថា ត្រង់ចំណុច MOU នេះគឺយើងត្រូវដាក់បញ្ចូលបន្ថែមរវាងកម្ពុជា ជាមួយចិន និងឥណ្ឌា ឯកភាពចំពោះការកែប្រែកាលបរិច្ឆេទច្បាប់ស្តីពីសញ្ជាតិ និងបញ្ហា MOU ជាមួយថៃ និងវៀតណាម ។ ចំពោះចំណុចទី៤ ការពង្រឹងសុខុមាលភាពសេដ្ឋកិច្ចសង្គមរបស់ជនទេសន្តរប្រវេសន៍ ក្នុង ៤.១.តើយើងត្រូវដាក់បន្ថែមបានទេទាក់ទងទៅនឹងយន្តការផ្សេងៗដែលកម្ពុជាបានធ្វើ ដូចជាការពង្រឹងសុខុមាលភាព សេដ្ឋកិច្ចសង្គមជនទេសន្តរប្រវេសន៍ និងសង្គម ដោយសារក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខិតខំប្រឹងប្រែងបង្កើតឲ្យមានការឱកាសការងារសម្រាប់ពលករវិលត្រឡប់ ជាង២ម៉ឺនកន្លែង ហើយក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈមិនត្រឹមតែមិនឲ្យបង់ថ្លៃសាលាទេ គឺថែមទាំងមានការឧបត្ថម្ភបន្ថែមទៀតចំពោះអ្នកណាបានទៅរៀនវិជ្ជាជីវៈនេះ ។ ចំណុច ផ្សព្វផ្សាយអប់រំនេះផងដែរ គិតថាយើងអាចដាក់បញ្ចូលបានទេ?ទាក់ទងទៅនឹងការផ្សព្វផ្សាយដោយបញ្ចូលទៅក្នុងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដែលនិយាយអំពីការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព មានន័យថា គឺឲ្យគាត់ធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់តាមរយៈការកែលម្អគោលនយោបាយផ្សេងៗទាក់ទងនឹងផ្លូវច្បាប់ ដូចជាការផ្តល់ជូន លិខិតឆ្លងដែន ទិដ្ឋាការការងារ និងការបញ្ចុះតម្លៃលើសេវាជារណៈជាដើមក្នុងការស្វែងរកការងារធ្វើនៅក្រៅប្រទេសជាដើមសម្រាប់ពលករ ។ ចំពោះចំណុចទី៥ (៥.២) ទាក់ទងគ្រោះមហន្តរាយ ដែលជាផែនការសកម្មភាពថ្មី ២០១៩-២០២៣ ត្រូវបានព្រាងឡើងដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ តែកំពុងរង់ចាំការអនុម័ត ទន្ទឹមនឹងនោះរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសារធារណៈ ដល់ពលរដ្ឋដែលបានត្រឡប់មកវិញដូចពលរដ្ឋដែលរស់នៅក្នុងប្រទេស គឺទទួលបានការផ្តល់សេវាដូចគ្នា នេះក៏ជាគោលនយោបាយរបស់យើងដែរ ។ ចំណុចទី៦ ធានាឲ្យបានទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (៦.១) អភិបាលកិច្ចទេសន្តរប្រវេសន៍៖ ការគ្រប់គ្រងព្រលានយន្តហោះ កំពង់ផែសមុទ្រកម្ពុជា យើងគួតែនិយាយអំពីព្រំដែនគោកផងដែរ មិនមែនពាក់ព័ន្ធតែក្រសួងមហាផ្ទៃតែមួយទេ គឺក្រសួងការពារជាតិក៏មានការពាក់ព័ន្ធនឹងការងារការពារព្រំដែនទឹក និងគោកផងដែរ ដែលយើងបានសហការគ្នាក្នុងការគ្រប់គ្រងការចេញចូលពលករទេសន្តរប្រវេសន៍ ។ **លោកជំទាវ** បានលើកជាសំណើរថា គួរដាក់បញ្ចូលដែរ

ទេ? យើងមិនទាន់មានគោលនយោបាយការពារសិទ្ធិកុមារក្នុងទេសន្តរប្រវេសន៍ គឺជាកុមារដែលធ្វើទេសន្តរប្រវេសន៍ដោយខ្លួនឯង ទៅតាមគ្រួសារ ឬត្រូវគ្រួសារបោះបង់ឲ្យនៅនៅឯស្រុក ដោយសារតែមានកុមារមួយចំនួននៅក្នុងប្រទេសគោលដៅចង់ឲ្យមានការការពារសមស្រប និងធ្វើការអភិវឌ្ឍរយៈពេលយូរអង្វែងនៅពេលដែលពួកគាត់ដល់វ័យត្រូវការពារ ដូចជាករណីពេលពួកគាត់កើតនៅប្រទេសក្រៅ គឺខ្វះអត្តសញ្ញាណ សំបុត្រកំណើត និងការផ្តល់នូវសញ្ជាតិដល់គាត់ កុំឲ្យអ្នកជំនាន់ក្រោយទៀតកាន់តែមានការកំបាកជាងនេះទៅទៀត ពាក់ព័ន្ធនឹងខ្វះការរៀនសូត្រ ខ្វះចំណេះដឹងផ្នែកវប្បធម៌ អក្សរសាស្ត្រខ្លួន ពេលគាត់ត្រឡប់មកវិញគឺគាត់ជួបបញ្ហាការសម្របខ្លួននៅក្នុងសង្គមរបស់ខ្លួនឯង គ្មានញាតិសណ្តានដែលធ្វើឲ្យមានបញ្ហា ។

៣.**ឯកឧត្តម ម៉ូច ម៉ុណ្ណរ៉ាក់** រដ្ឋលេខាធិការក្រសួងផែនការ មានប្រសាសន៍ចូលរួមពាក់ព័ន្ធទំព័រ១២ ត្រង់កថាខណ្ឌ ជំរឿនប្រជាជនកម្ពុជាទាក់ទងនឹងការធ្វើទេសន្តរប្រវេសន៍ ហើយនិងកថាខណ្ឌចុងក្រោយពាក់ព័ន្ធក្រសួងផែនការបានផ្សព្វផ្សាយរបាយការណ៍ ៣ លើក ។ **ឯកឧត្តម** បានបញ្ជាក់សួរថា តើរបាយការណ៍ ឬព័ត៌មានណាខ្លះដែលខាងក្រុមការងារចង់បានដើម្បីធ្វើជារបាយការណ៍? ហេតុផលគឺ ក្រសួងផែនការមានគម្រោងធំៗ ៣ ទាក់ទៅនឹងទេសន្តរប្រវេសន៍ ទី១.ជំរឿន ទី២.អង្កេតជំរឿន ទី៣.អង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ករណីនេះមានរបាយការណ៍រួមមួយ និងមានរបាយការណ៍ដោយឡែកចំនួន១០ ក្នុងនោះមានរបាយការមួយនិយាយពីទេសន្តរប្រវេសន៍ និងនគរូបនីយ៍កម្ម បើចង់បានទិន្នន័យទេសន្តរប្រវេសន៍ខ្ញុំនឹងរៀបចំជូនតាមការចង់បាន ។ ចំពោះ ទី២ នៅក្នុងកថាខណ្ឌ ចុងក្រោយ និយាយពីការធ្វើរបាយការណ៍ចំនួន ៣ (ទី១) និយាយអំពីគោលនយោបាយប្រជាជន គឺមិនមែនជារបាយការណ៍ ។

៤.**ឯកឧត្តម ហ៊ី ខុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ចូលរួមពាក់ព័ន្ធនឹងរបាយការណ៍នេះ គឺមិនត្រឹមតែសម្រាប់ប្រទេសកម្ពុជាយើងប៉ុណ្ណោះទេ គឺនឹងត្រូវផ្ញើជូនទៅអង្គការសហប្រជាជាតិទៀតផង ដែលតម្រូវឲ្យស្ថាប័ននីមួយៗ ត្រូវទទួលខុសត្រូវចំពោះការដាក់បញ្ចូលទិន្នន័យណាមួយទៅក្នុងរបាយការណ៍នេះ ។ **ឯកឧត្តម** បានលើកឡើងអំពីការទទួលខុសត្រូវ ដែលក្រសួង ស្ថាប័នពាក់ព័ន្ធបានបញ្ជូនសមាសភាពមក គឺមួយចំនួនដូចជាមិនទាន់មានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយឡើយ និងមិនទាន់ក្តាប់ព័ត៌មានច្បាស់អំពីក្រសួងរបស់ខ្លួនផងដែរ ចំណុចមួយទៀត គឺ ខាងអង្គការ IOM មិនទាន់ក្តាប់បានលើព័ត៌មានដែលក្រសួង ស្ថាប័នពាក់ព័ន្ធមានការកែប្រែ ។

៥.**ឯកឧត្តម នាយឧត្តមសេនីយ៍ ឃុន សំបូរ** អគ្គនាយករងដ្ឋាន នៃអគ្គនាយដ្ឋានអន្តោប្រវេសន៍ មានមតិពាក់ព័ន្ធទៅនឹងការផ្តល់ជារបាយការណ៍ ដើម្បីបំពេញបន្ថែមសូចនាករនេះថា ការងារខ្លះមានចំណុចរួមជាអន្តរក្រសួង ស្ថាប័ន និងមានចំណុចខ្លះដាច់ដោយឡែក ។ **ឯកឧត្តម** បានលើកពីចំណុចមួយពាក់ព័ន្ធនឹងការចូលសញ្ជាតិ វាពាក់ព័ន្ធនឹងច្បាប់របស់ក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ យើងមាន ៣ លក្ខខណ្ឌ **ទី១.** ទេសន្តរប្រវេសន៍ SOM គឺគាត់ចូលរស់នៅក្នុងប្រទេសកម្ពុជារយៈពេល៧ឆ្នាំ ដោយមិនមានទោសទណ្ឌ ឬបានប្រព្រឹត្តបទល្មើសណាមួយ គឺគាត់អាចចូលសញ្ជាតិបាន **ទី២.**ទេសន្តរប្រវេសន៍ SOM ដដែលបានរៀបការជាមួយស្ត្រីខ្មែរ ដូច្នេះគូបនីយ៍កម្មអាពាហ៍ពិពាហ៍គាត់អាចសុំចូលសញ្ជាតិបាន **ទី៣.**ជនបរទេសដែលគាត់មករកស៊ី និងដាក់ទុនធ្វើជំនួញនៅកម្ពុជា គាត់បានស្នាក់នៅស្របច្បាប់តាមការកំណត់របស់រដ្ឋាភិបាល គាត់ក៏អាចសុំចូលសញ្ជាតិបានដែរ ដូចនេះលក្ខខណ្ឌទាំង៣ ខាងលើយើងសរសេរក្នុងរបាយការណ៍បញ្ចូលគ្នាតែមួយ ។ ពាក់ព័ន្ធនឹងចំណុចនេះ យើងត្រូវពិភាក្សាគ្នាលើងវិញ ហើយចំពោះច្បាប់អន្តោប្រវេសន៍ ច្បាប់សញ្ជាតិ និងអនុក្រិត្យ១៨៣ បាន

ចែងផងដែរ ។ ចំណុចមួយទៀត គឺការកំណត់ទិដ្ឋាកា វាមានការពាក់ព័ន្ធជាមួយក្រសួងមហាផ្ទៃផង និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផងដែរ ក្នុងនោះយើងបានបែងចែកទម្រង់ទិដ្ឋាការួចហើយទៅតាមប្រភេទនីមួយៗ ឧទាហរណ៍ថា យើងបានកំណត់ A B C សម្រាប់ការទូត ឬអង្គការ ប្រភេទ D សម្រាប់ទេសចរណ៍ សម្រាប់ជនបរទេសមកធ្វើការ និងបានធ្វើការកំណត់ទិដ្ឋាកាសម្រាប់អ្នកធ្វើដំណើរឆ្លងកាត់ ។ ដូច្នេះសម្រាប់ជនបរទេសទេសន្តរប្រវេសន៍ដែលបានមកកម្ពុជា គឺបានកំណត់ហើយ មិនមែនមិនបានកំណត់ទេ ឲ្យតែគាត់មកស្នើសុំហើយគាត់អាចមកស្នើសុំបន្តទិដ្ឋាកាបាន យើងក៏មានការកំណត់ទិដ្ឋាអនុគ្រោះសម្រាប់ប្រទេសចិន និងកូរ៉េ រយៈពេល ១ឆ្នាំ ដល់ ៣ឆ្នាំ គាត់អាចចេញ-ចូលមកធ្វើការនៅកម្ពុជាបាន ។ ចំណុចមួយទៀត គឺការគ្រប់គ្រងទិដ្ឋាកាជនប្រទេសមកស្នាក់នៅប្រទេសកម្ពុជា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលជាសេនាធិការក្រសួងមហាផ្ទៃ គឺយើងបានអនុវត្តការងារនេះបានត្រឹមត្រូវ ដោយប្រើប្រាស់ឧបករណ៍ចំនួន ៩ សម្រាប់ធ្វើការគ្រប់គ្រងបញ្ហានេះ យើងអាចដឹងថាទិដ្ឋាកាណាលើសកំណត់ និងមិនលើសកំណត់ តែយើងក៏មានចំណុចខ្សោយផងដែរលើបញ្ហានេះ ដោយយើងបានដឹងហើយថាឈ្មោះណាលើសកំណត់ គឺយើងរកគាត់អត់ឃើញ ។ ដូច្នេះថ្មីៗនេះ យើងមានឧបករណ៍មួយទៀតសម្រាប់គ្រប់គ្រងការស្នាក់នៅ និងកន្លែងធ្វើការរបស់ជនបរទេសទាំងនោះ ដោយប្រើប្រាស់ប្រព័ន្ធ App យើងមានទាំងឧបករណ៍គ្រប់គ្រងបញ្ជីខ្មៅជនបរទេសដែលកំពុងធ្វើការនៅកម្ពុជាផងដែរ ។ បញ្ហាមួយទៀត គឺការគ្រប់គ្រងពលករកម្ពុជា អង្គការ IOM បានជួយច្រើនណាស់សម្រាប់ពលករត្រឡប់មកពីបរទេស ទាំងនៅក្នុងដំណាក់កាលជំងឺកូវីដ-១៩ នេះ ។

## VI.កិច្ចពិភាក្សាជាក្រុម

បន្ទាប់មក គណៈធិបតី សមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងអស់បានធ្វើការបែងចែកជា ៣ ក្រុម ដើម្បីធ្វើការពិភាក្សាលើសំនួរពាក់ព័ន្ធសូចនាករ ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ សូចនាអភិបាលកិច្ចទេសន្តរប្រវេសន៍ MGI ដោយធ្វើការបែងចែកជា ៣ក្រុម រួមមាន៖

-ក្រុមទី១. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការ IOM (ការធ្វើទេសន្តរប្រវេសន៍ ប្រព្រឹត្តទៅដោយស្ម័គ្រចិត្ត រៀបរយ និងស្របច្បាប់) គោលបំណងកតិកាសញ្ញា៖ ២,៥,៦,១២,១៨

-ក្រុមទី២.ក្រសួងសុខាភិបាល អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អង្គការ IOM (ការពារទេសន្តរប្រវេសន៍ តាមរយៈវិធានការអភិបាលកិច្ចព្រំដែនដោយផ្តោតលើសិទ្ធិ) គោលបំណងកតិកាសញ្ញា៖ ៤,៨,៩,១០,១១,,១៣,២១

-ក្រុមទី៣. គណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គាំទ្រការដាក់បញ្ចូលជនទេសន្តរប្រវេសន៍ និងការរួមចំណែករបស់ពួកគេ ក្នុងការងារអភិវឌ្ឍន៍) គោលបំណងកតិកាសញ្ញា៖ ១៤,១៥,១៦,១៩,២០,២២ ។

បន្ទាប់ពីធ្វើការពិភាក្សាជាក្រុម អង្គសិក្ខាសាលាទាំងមូលបានធ្វើការពិភាក្សាបន្តលើប្រធានបទ (ធ្វើឲ្យប្រសើរឡើងនូវការបង្កើតគោលនយោបាយ និងការជជែកវែកញែកជាសាធារណៈដើយផ្អែកលើភស្តុតាង ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការលើការងារទេសន្តរប្រវេសន៍) គោលបំណងកតិកាសញ្ញា៖១,៣,៧,១៧,២៣ និង ប្រធានបទ (តើរដ្ឋាភិបាលចាត់វិធានការអ្វីខ្លះ ដើម្បីដាក់បញ្ចូលចក្ខុវិស័យ និងគោលការណ៍ណែនាំ នៃកតិកាសញ្ញាពិភពលោក ទៅក្នុងការអនុវត្តរបស់ខ្លួន? តើសម្រេចបានដោយរបៀបណា?

## VII.លទ្ធផលសិក្ខាសាលា និងប្រសាសន៍ដឹកនាំ

សំណួរទី ៣កះ គោលនយោបាយ

គោលបំណង ១៤ះ

- តាមការអនុវត្តជាក់ស្តែង ស្ថានទូត ស្ថានអគ្គកុងស៊ុល ជួយសម្របសម្រួលការងារផ្សេងៗ គាំទ្រសិទ្ធិពលករ ពលរដ្ឋខ្មែរ ការពារផលប្រយោជន៍ពលករ។
- ជួយបញ្ជាក់ឯកសារនីត្យានុកូលកម្មផ្សេងៗ
- ជ្រុមជ្រែងការពារផ្លូវច្បាប់ ផ្លូវតុលាការ ជួយដល់ពលរដ្ឋខ្មែរ
- បង្ករលក្ខណៈងាយស្រួលសម្រាប់មាតុភូមិនិវត្តន៍ និងចេញលិខិតបញ្ជាក់ ការធ្វើដំណើរ
- ការបន្តផ្តល់ប័ណ្ណផ្តល់ភាពស្របច្បាប់ដល់ទេសន្តរប្រវេសន៍

គោលបំណង ១៥ះ

- MOLVT គ្រប់គ្រងលើការធ្វើទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយ MFAIC និង MoI
- MOLVT បានបង្កើត និងអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារះ
    - អភិបាលកិច្ចកាន់តែប្រសើរ
    - លើកកំពស់ និងការពារសិទ្ធិពលករ
    - ការអភិវឌ្ឍ ដោយទទួលបានជំនាញ កាត់បន្ថយការអត់ការងារធ្វើ
- មានការអភិវឌ្ឍល្អសេវាសុខភាពកម្ពុជា ត្រូវបានដាក់បញ្ចូលក្នុងរបបសន្តិសុខសង្គម។ពលករទេសន្តរប្រវេសន៍ស្របច្បាប់ មានសិទ្ធិស្មើគ្នា នឹងប្រជាពលរដ្ឋក្នុងប្រទេស។
- ការពង្រឹងសខុមាលភាពសេដ្ឋកិច្ចសង្គម
- ការលើកម្ពស់សុខមាលភាពេសេដ្ឋកិច្ចសង្គម និងរបស់ជនទេសន្តរប្រវេសន្ត

គោលបំណង ១៦ះ

- ទទួលបានការអប់រំដោយមិនគិតថ្លៃ ៦ឆ្នាំ សម្រាប់ជនទេសន្តរប្រវេស ៩ឆ្នាំ
- លើកកំពស់ការយល់ដឹងស្តីពីឯកសារ និងបទបញ្ញត្តិពាក់ព័ន្ធទេសន្តរប្រវេសន៍ការងារ
- លើកំពស់យ៉េនឌ័រនៅក្នុងកំលាំងពលកម្មការងារ
- លើកទឹកចិត្តឲ្យមានទំនាក់ទំនងដោយផ្ទាល់ជាមួយស្ថានកុងស៊ុល រឺស្ថានទូត
- ផ្សព្វផ្សាយទូលំទូលាយពាក់ព័ន្ធច្បាប់ទេសន្តរប្រវេសន៍ និងច្បាប់ដទៃទៀត
- គោលនយោបាយគាំទ្រការវិលត្រលប់ និងការធ្វើសមាហរណកម្មជនទេសន្តរប្រវេសន្ត (ក្រសួងការងារ)

គោលបំណង ២២ះ

- ទទួលបានសេវាសុខភាព តាមរយៈរបបសន្តិសុខសង្គម
- សេចក្តីព្រៀងគោលនយោបាយជាតិស្តីពីសុខភាពសម្រាប់ជនទេសន្តរប្រវេសន្ត
- គោលនយោបាយជាតិគាំពារសង្គម ២០១៦__២០២៥

គោលបំណង ២០ះ

សំណួរទី ៣ខះ បញ្ហាប្រឈម

- ពិបាកនៅក្នុងការគ្រប់គ្រងលំហូរសាច់ប្រាក់របស់ជនទេសន្តរប្រវេសន្ត

- កង្វះធនធានមនុស្ស ធនធានថវិកាក្នុងការជួយសង្គ្រោះជនចំណាកស្រុកមានបញ្ហា
- កង្វះការសហការពីអាជ្ញាធរមូលដ្ឋានបរទេស (ឧ.ប្រទេសថៃ ចិន ម៉ាឡេស៊ី)
- បញ្ហាចំណាកស្រុកខុសច្បាប់នៅតែបន្ត បណ្តាលឲ្យមានការបញ្ជូនចេញ និងបាត់បង់កម្រៃ
- ការចាញ់បោកមេខ្យល់ ឈ្មួញនៅតែបន្តមាន

សំណួរទី ៣គ៖ ដំណោះស្រាយ

- ករណីស្ថានភាពប្រសើរ រដ្ឋាភិបាលគួរពិចារណាបន្ថែមថវិកាជាតិដើម្បីដោះស្រាយបញ្ហាសម្រប សម្រួលមាតុភូមិនិវត្តន៍ និងការគាំទ្រផ្សេងៗ
- ជំរុញការបណ្តុះបណ្តាលពលរដ្ឋ ចំពោះចំណាកស្រុកដោយសុវត្ថិភាព
- សហការជាមួយដៃគូអភិវឌ្ឍនានា ពិសេសអង្គការជាតិ និងអន្តរជាតិ
- ពង្រឹងកិច្ចសហការជាមួយប្រទេសគោលដៅ ឬរកយន្តការរួមមួយ ទ្វេភាគី ឬពហុភាគី
- ផ្តល់ព័ត៌មានអាចជឿជាក់ រហ័ស និងដល់ដៃពលរដ្ឋ

សំណួរទី ៤ក៖ គោលនយោបាយ

- កន្លងមកចាប់ពីឆ្នាំ ២០១៩ រដ្ឋាភិបាលពិភាក្សាជាមួយប្រទេស CMLTV ថ្នាក់តំបន់រួមគ្នាដោះ ស្រាយបញ្ហាទេសន្តរប្រវេសន៍
- កម្ពុជាបន្តផ្តល់ភាពស្របច្បាប់ដល់ពលករនៅបរទេស
- ពង្រឹងអាជ្ញាធរពាក់ព័ន្ធ ឬគណៈកម្មាធិការដោះស្រាយបញ្ហា។

សំណួរទី ៤ខ៖ បញ្ហាប្រឈម

- កង្វះធនធានមនុស្ស ថវិកា ការប្តេជ្ញាចិត្ត
- ដោយសារភាពក្រីក្រ ពលរដ្ឋនៅតែព្យាយាមធ្វើទេសន្តរប្រវេសន៍
- ពលរដ្ឋខ្វះចំណេះដឹង និងកង្វះព័ត៌មានជាក់លាក់
- អាជ្ញាធរបរទេស ឬប្រទេសគោលដៅពុំសហការបានល្អ។

សំណួរទី ៤គ៖ ដំណោះស្រាយ

- IOM ជួយសម្របសម្រួលប្រទេសក្នុងតំបន់ជួយសហការដោះស្រាយ
- ស្ថាប័នរដ្ឋ ឯកជន ជួយផ្សព្វផ្សាយបន្តដល់ពលរដ្ឋផ្ទាល់
- ពង្រឹងសមត្ថភាពធនធានមនុស្ស

Q3a.

- MoLVT manage labour migration in cooperation with MFAIC and MOI
- MoLVT established and implemented the Policy on Labour Migration
- Good governance
- Protection and empowerment of migrant workers
- Development of skills and reduction of unemployment
- In real practice, the Embassies and the Consulates assist citizens living abroad including supporting the rights and protecting the benefit of migrants.
- Legalization of documents
- Support for its citizens to return home country and issuing travel documents.
- Continue providing certificate to irregular migrants so that they can become regular migrant workers

Q3b.

- Lack of financial and human resources in assisting migrants when they are having problems
- Lack of cooperation from destination countries such as Thailand, China and Malaysia.
- Irregular migration is still a problem which cause the lost of money and irregular migrant still being sent out to their home country.
- Labour exploitation still exists.

Q3C.

- Government should consider increase the budget in assisting the returnees and other related works.
- Disseminate information regarding safe migration
- Cooperate with development partners especially NGOs and INGOs
- Strengthen cooperation with receiving country or seeking for bilateral or multilateral mechanism.
- Provide reliable and rapid information to potential migrants

Q4a.

- Government discussed with CMLVT countries to address migration works
- Government of Cambodia still continue to provide legal status for their migrant workers working abroad.
- Strengthening relevant authority or comm

មុនការបញ្ចប់សិក្ខាសាលា **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើការស្នើសុំជាថ្មីម្តងទៀតចំពោះ ឯកឧត្តម លោកជំទាវ លោក លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្តល់នូវរបាយការណ៍ ឯកសារពាក់ព័ន្ធនឹងកតិកាសញ្ញាពិភពលោកឲ្យបានឆាប់រហ័ស ។ លោកជំទាវ ក៏សូមឲ្យគ្រប់ក្រសួង ស្ថាប័ន រៀបចំចងក្រងរបាយការណ៍ពាក់ព័ន្ធការអនុវត្តន៍ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពីឥឡូវនេះរហូតដល់ឆ្នាំ២០២២ សម្រាប់ដាក់បញ្ចូលក្នុងកតិកាសញ្ញាពិភពលោក ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃ [illegible] ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២០

**អ្នកធ្វើរបាយការណ៍**

ឧត្តមសេនីយ៍ទោ. អ៊ុំ ភាមិន្ទ

**សូមគោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់

ថ្ងៃ [illegible] ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២០

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណា សំខាន់

21/01/2021

ជូ_ប៊ុនអេង